EMERGENCY SERVICES

សេវាកម្មក្នុងគ្រាអាសន្ន

តើលោកអ្នកស្ថិតក្នុងស្ថានភាពបាត់បង់ផ្ទះឬទេ ?

តើលោកអ្នកគ្មានប្រាក់ទូទាត់សំរាប់ថ្លៃឈ្នួល ការបង់រំលោះ ឬបង់វិក្ក័យប័ត្រទឹក/ភ្លើងឬទេ ?

តើលោកអ្នកត្រូវការជំនួយសំរាប់ចំណាយលើការផ្ទាស់ប្តូរទីកន្លែងស្នាក់នៅឬទេ ?

ប្រសិនបើលោកអ្នកផ្ញើយថា បាទ/ចាស់ ចំពោះសំណួរណាមួយក្នុងចំណោមសំណួរទាំងនេះ CTI អាចជួយលោកអ្នកបាន ។

ការគាំទ្រមតិ - ការិយាល័យគាំទ្រមតិរបស់ CTI ប្រើប្រាស់មូលនិធិនានា ដើម្បីទូទាត់ចំណាយសេវាដែលមិនសមស្រប នឹងកម្មវិធីធម្មតា ។ មូលនិធិអាចយកមកទូទាត់លើការស្នាក់នៅជាបន្ទាន់ក្នុងសណ្ឋាគារ ថ្លៃជួល ចំណាយលើការផ្ទាស់ប្តូរ ទីកន្លែងស្នាក់នៅ ចំណាយលើការធ្វើដំណើរសំរាប់ការងារ វិក្ក័យប័ត្រប្រេងឥន្ធនៈ វិក្ក័យប័ត្រមួបអាហារ និងចំណាយសុខ ភាពដែលកើតឡើងយូរ១ម្តង ដូចជាចំណាយលើការព្យាបាល វ៉ែនតា ។ល។

សំរាប់ព័ត៌មានបន្ថែមអំពីការិយាល័យគាំទ្រមតិ សូមទូរស័ព្ទមកលេខ (៩៧៨) ៤៥៩-០៥៥១ លេខភ្ជាប់ ២០៤

RAFT (ជំនួយលើថ្លៃជួលផ្ទះសំរាប់ក្រុមគ្រួសារក្នុងជំណាក់កាលបណ្តោះអាសន្ន) - កម្មវិធីនេះត្រូវបានបង្កើត ឡើងដើម្បីជួយការពារអ្នកគ្មានកន្លែងស្នាក់នៅ តាមរយៈការទូទាត់ចំណាយលើការជួលនៅខែទីមួយ និងខែចុងក្រោយ និងប្រាក់ធានាលើទីកន្លែងស្នាក់នៅថ្មី ។ កម្មវិធីនេះ នឹងជួយក្រុមគ្រួសារដែលជំពាក់ថ្លៃជួលផ្ទះគេ ឬដែលបានទទួលលិខិត ជូនដំណឹងផ្តាច់ចរន្តពីក្រុមហ៊ុនផ្គត់ផ្គង់ទឹក/ភ្លើង ។

លក្ខខណ្ឌតំរូវ : គ្រួសារនីមួយ១ ត្រូវមានសិទ្ធិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូល តែមិនអាចទូទាត់ចំណាយជួលផ្ទះលើសពី ៥០% នៃចំណូលរបស់គ្រួសារខ្លួនបាន ។ គ្រួសារនេះត្រូវមានចំណូលគ្រួសារអោយបានគ្រប់គ្រាន់ ដើម្បីបង្ហាញពីលទ្ធភាពទូទាត់ចំណាយលើការជួលផ្ទះប្រកបដោយនិរន្តរភាព បន្ទាប់ពីប្រើប្រាស់មូលនិធិរបស់ RAFT រួច ។

សំរាប់ព័ត៌មានបន្ថែមអំពី RAFT សូមទូរស័ព្ទមកលេខ (៩៧៨) ៤៥៩-០៥៥១ លេខភ្ជាប់ ២០៤/២៦៧/២៩០ ឬ ២៩៧ ។

FEMA (ភ្នាក់ងារសហព័ន្ធគ្រប់គ្រងភាពអាសន្ន)

កម្មវិធីនេះផ្តល់មូលនិធិតែមួយលើក ដើម្បីជួយបុគ្គលទាំងឡាយណា ដែលស្ថិតក្នុងស្ថានភាពបាត់បង់ផ្ទះសំបែងរបស់ខ្លួន។ FEMA អាចជួយទូទាត់ចំណាយលើការជួលរយៈពេលមួយខែ ឬចំណាយបង់រំលោះ ។ មូលនិធិរបស់ FEMA ក៏អាចត្រូវបានប្រើប្រាស់ដើម្បីទូទាត់ចំណាយលើការជួលនៅខែដំបូងសំរាប់ក្រុមគ្រួសារទាំងឡាយណា ដែលគ្មានផ្ទះសំបែង និងដែលកំពុងផ្ទាស់ទីលំនៅទៅកន្លែងស្នាក់នៅថ្មី ។

លក្ខខណ្ឌតំរូវ : ដើម្បីមានសិទ្ធិក្រោមកម្មវិធីនេះ អ្នកត្រូវមានលិខិតជូនដំណឹងអោយរើចេញពីកន្លែងស្នាក់នៅក្នុងរយៈ ពេល ១៤ថ្ងៃ (លិខិតបណ្តេញចេញ) ។ ម្ចាស់ផ្ទះត្រូវផ្តល់របាយការណ៍ស្តីពីចំណាយ បង់រំលោះ ដែលបង្ហាញថា ពួកគេយ៉ាងហោចណាស់មិនបានទូទាត់រយៈពេលមួយខែមកហើយ ។ ប្រាក់ចំណូលរបស់លោកអ្នក ត្រូវមានចំនួនលើសពីថ្លៃជួល ផ្ទះ ឬចំណាយបង់រំលោះរបស់ខ្លួនយ៉ាងហោចណាស់ក៏ ១ ដុល្លារដែរ ដើម្បីអាចអោយលោកអ្នកមានសិទ្ធិក្រោមកម្មវិធី FEMA ។

សំរាប់ព័ត៌មានបន្ថែមអំពី FEMA សូមទូរស័ព្ទមកលេខ ៩៧៨-៤៥៩-០៥៥១ លេខភ្ជាប់ ២០៤/២៦៧/២៩០ ឬ ២៩៧ ។

កម្មវិធីជំនួយលើផ្ទះសំបែង — ប្រអប់ជំនួយ

ប្រភពមូលនិធិជាបន្ទាន់នេះ ជួយក្រុមគ្រួសារទាំងឡាយអោយរក្សាបានទីលំនៅអចិន្ត្រៃយ៍ ។ កម្មវិធីនេះ ក៏ជួយគ្រួសារទាំងឡាយណាដែលរងការគំរាមបណ្តេញចេញពីកន្លែងស្នាក់នៅផងដែរ ។ មូលនិធិនេះ អាចត្រូវបានគេប្រើសំរាប់ទូទាត់ ថ្លៃជួលសំរាប់ខែដំបូង និងខែចុងក្រោយ និងប្រាក់ធានា ។ មូលនិធិទាំងនេះ អាចត្រូវយកមកប្រើសំរាប់ចំណាយលើការ ផ្ទាស់ប្តូរទីលំនៅផងដែរ ។

លក្ខខណ្ឌតំរូវ : គ្រួសារទាំងឡាយ អាចមានសិទ្ធិក្រោមកម្មវិធីជំនួយជាបន្ទាន់ តាមរយៈនាយកដ្ឋានជំនួយបណ្តោះអាសន្ន ។ គ្រួសារទាំងនេះត្រូវមានលទ្ធភាពបន្តទូទាត់ថ្លៃជួលផ្ទះ បន្ទាប់ពីមូលនិធិរបស់ប្រអប់ជំនួយនេះ ត្រូវបានយកមកប្រើប្រាស់ ។

សំរាប់ព័ត៌មានបន្ថែមអំពីប្រអប់ជំនួយ សូមទូរស័ព្ទមកលេខណាមួយក្នុងចំណោមលេខទូរស័ព្ទខាងក្រោម :

៩៧៨-៤៤៦-២៤៤៦ ៩៧៨-៤៤៦-២៤១៥ ៩៧៨-៤៤៦-២៤៧៤